ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាផ្នែក ព្រហ្មទណ្ឌ
សំណុំរឿង ព្រហ្មទណ្ឌ
លេខ : ៣៨
ចុះថ្ងៃទី២៥-៩-៩៨

សាលដីកា
លេខ: ០៦
ចុះថ្ងៃទី០៣-៣-៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុ លា កា រ កំ ពូ ល

ក្នុងបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៩ ដោយមានសមាសភាពដូចតទៅ :

១ - ឯកឧត្តម ឌិត មុន្ទី ជាប្រធាន
២ - លោក ឈឹម ស៊ីផុន ចៅក្រម
៣ - លោក សោម សិរីវុឌ្ឍ ចៅក្រម
៤ - លោក ប្រាក់ គឹមសាន ចៅក្រមរបាយការណ៍
៥ - លោក យស់ សូខឿន ចៅក្រម

លោក ខ៉ាន់ បូរ៉ាត ក្រឡាបញ្ជី
តំណាងមហាអយ្យការលោក សាយ សារី ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ១៨៤ ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ ៣៨ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ-១៩៩៨ របស់តុលាការកំពូល

ពីបទ : ភេរវកម្ម ចាប់ជំរិតមនុស្សយកប្រាក់ ប្រព្រឹត្តកាលពីថ្ងៃទី១០ ខែ សីហា ឆ្នាំ ១៩៩៧ នៅក្រុងភ្នំពេញ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា០២ នៃច្បាប់ស្តីពីការផ្តន្ទាទោសអំពីរឿងភេរវកម្ម ។

- ជនជាប់ចោទឈ្មោះ ម៉េត ខាន់ម៉េង ហៅតូ ភេទប្រុស អាយុ ២៧ ឆ្នាំជាតិខ្មែរ របររកស៊ី នគរបាលគ្រឿងញៀន កើតនៅសង្កាត់លេខ ២ ក្រុងភ្នំពេញ ទីលំនៅមុនពេលចាប់ខ្លួន ផ្ទះគ្មានលេខ ផ្លូវលេខ ៣០០ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន ក្រុងភ្នំពេញ ឪពុកឈ្មោះ ម៉េង សាខាន់ " រស់ " ម្តាយឈ្មោះ ក្រៀល ចាន់ធី " រស់ " នៅសើរ ។

- មេធាវី លោក ជា តារា " ជាម្ចាស់បណ្តឹងសាទុក្ខ "

- ជនរងគ្រោះឈ្មោះ ឈួ សារិទ្ធិ ហៅ លឹម អាយឡុង " ជាចុងបណ្តឹងសាទុក្ខ " ភេទប្រុស អាយុ ៤០ឆ្នាំ ទីលំនៅផ្ទះលេខ៩៥អ៊ី០ ផ្លូវកម្ពុជាក្រោម សង្កាត់មិត្តភាពខណ្ឌ៧មករា ក្រុងភ្នំពេញ ។ មេធាវី ឬ អ្នកការពារ គ្មាន ។/

- តាមបណ្តឹងសាទុក្ខលេខ ៣៧ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៨ របស់លោកមេធាវី ផា តារា ការពារអោយជនជាប់ចោទ ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ១៨៤ ចុះថ្ងៃទី-២៨ ខែ សីហា ឆ្នាំ ១៩៩៨ របស់សាលាដំបូងរាជធានី លើសេចក្តីសំរេចទាំងមូល ។

- តាមរបាយការណ៍លេខ ៨៤.៩៧ ចុះថ្ងៃទី០១ ខែ កញ្ញា ឆ្នាំ ១៩៩៧ ការិយាល័យនគរបាលព្រហ្មទណ្ឌកិច្ចនៃរាជធានីភ្នំពេញ បានរាយការណ៍ថា កាលពីថ្ងៃទី ២០-៨-៩៧ វេលាម៉ោង១៧.០០ មានអំពើភេរវកម្មចាប់មនុស្សជំរិតយកប្រាក់ នៅត្រង់ចំណុចមុខវត្តបក្ខានតាព្រហ្ម ខាងត្បូងស្ពានស្ទឹងមានជ័យ ក្នុងខណៈដែលលោក ស៊ួ សារិទ្ធិ ហៅ លឹម ឆាយថុង ជិះរថយន្តចេញពីក្រុមហ៊ុនបេតុងតុងគុន ពេលនោះជនល្មើសបានបើករថយន្តមកកៀររថយន្តជនរងគ្រោះអោយងាកទៅចិញ្ចើមថ្នល់ខាងឆ្វេង ។ រួចជនល្មើសពីរនាក់ស្លៀកខោរបាំ អាវស៊ីវិល ពាក់ស្រោមជើងពាក់ស្រោមមុខ កាន់អាវុធ អាកាព្វាយបាញ់ពីរដើមចាប់ជនរងគ្រោះបញ្ចូលឡានរបស់ពួកវា ហើយបើកឆ្លងស្ពានទៅទិសខាងជើង ចូលមកក្រុងភ្នំពេញ ។ លុះដល់ម៉ោង ១៩.០០ថ្ងៃដដែលជនល្មើសបានទូរស័ព្ទមកទាមទារប្រាក់ពីប្រពន្ធជនរងគ្រោះចំនួន៣០០.០០០ដុល្លារអាមេរិក រួចចុះមកចំនួន១២០.០០០ដុល្លារអាមេរិក លុយរៀល-២លានរៀល ខ្សែកមាស១ខ្សែ ក្រោយមកជនល្មើសទទួលប្រាក់ពីប្រពន្ធជនរងគ្រោះនៅម៉ោង ២០.៣០នាទីថ្ងៃទី២១-៨-៩៧ ហើយជនល្មើសបានដោះលែងជនរងគ្រោះឈ្មោះ ស៊ួ សារិទ្ធិ ហៅ លឹម ឆាយថុង វិញ ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការក្រុងភ្នំពេញលេខ៣១៦ចុះថ្ងៃទី២៧-០២-៩៨ សុំរេចបោទប្រកាន់លើឈ្មោះ ចេង ខាន់ដែន ហៅតូ ភេទប្រុស អាយុ២៦ឆ្នាំ ពីបទ ប្រព្រឹត្តអំពើភេរវកម្ម ចាប់មនុស្សជំរិតយកប្រាក់ ប្រព្រឹត្តនៅភ្នំពេញ កាលពីថ្ងៃទី២០-៨-៩៧ តាមមាត្រា២នៃច្បាប់ស្តីពីការបង្ក្រាបទោសអំពើភេរវកម្ម និងបង្គាប់ប្តឹងអាជ្ញាលើអ្នកនេះ ។

- ទ្រៀងនេះតុលាការក្រុងភ្នំពេញបានសំរេចចាត់របៀបស៊ើបសួរបន្ថែមតាមអំណាចសាលក្រមត្រៀមលេខ ០២ "ឃ" ចុះថ្ងៃទី២៣-៤-៩៨ ហើយនៅថ្ងៃទី ២៤-៤-៩៨ លោក ផា តារា មេធាវីជនជាប់ចោទបានដាក់ពាក្យប្តឹងសុំអោយជនជាប់ចោទឈ្មោះ ចេង ខាន់ដែន នៅក្រៅឃុំជាបណ្តោះអាសន្ន ។

- តុលាការក្រុងភ្នំពេញបានសំរេចសេចក្តី សំរេចមុនអង្គសេចក្តីលេខ ០២ "ឃ" ចុះថ្ងៃទី-២៩-៤-៩៨ ដែលមានខ្លឹមសារដូចតទៅ :

១ - តម្កល់ការឃុំខ្លួនជនជាប់ចោទឈ្មោះ ចេង ខាន់ដែន ហៅតូ ភេទប្រុស អាយុ២៧ឆ្នាំរក្សាទុកនៅដដែល ។

២ - បដិសេធពាក្យសុំរបស់មេធាវីជនជាប់ចោទចុះថ្ងៃទី ២៤-៤-៩៨ ដែលសុំអោយជនជាប់ចោទឈ្មោះ ចេង ខាន់ដែន នៅក្រៅឃុំបណ្តោះអាសន្ន ជាអសារបង់ចាប់ពីពេលនេះតទៅ ។

- បានឃើញបណ្តឹងតវ៉ាលេខ០៨ "ឃ" ចុះថ្ងៃទី០៧-៥-៩៨ របស់មេធាវីជនជាប់ចោទ/

ដែលប្តឹងតវ៉ាពីសេចក្តីសំរេចមុនអង្គសេចក្តីលេខ០២ "ឃ" ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៨ ស៊ើសេចក្តីសំរេចមុនអង្គសេចក្តីទាំងមូល ។

- បាន ឃើញ សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ចុះថ្ងៃទី១៨ ៥-៩៨ ថា៖ នៅក្នុងសំណុំរឿងនេះមានបទល្មើសពីរផ្សេងទៀតដែលអយ្យការគ្មានការចាប់អារម្មណ៍
  - បទលួចទូរស័ព្ទ
  - បទជួយរំដោះផលចោរកម្ម , ទទួលទិញទូរស័ព្ទលួច , បទសមគំនិតដោយដូរលេខទូរស័ព្ទចាស់មកលេខថ្មី ។

ថ្ងៃបាត់ទូរស័ព្ទមានមិត្តភក្តិរួមតុក្នុងវគ្គសាលាចំនួន៤ឬ៥នាក់ ម្តេចគ្មាននរណាដឹង គ្មាននរណាជួយរក ឬ គ្រាន់តែជាកលល្បិច បង្ហាញថាមានបាត់ទូរស័ព្ទប៉ុណ្ណោះ ព្រោះឈ្មោះ ថេត ខ៉ាន់ដែន មានទូរស័ព្ទ ០២គ្រឿង លេខខ្មែរតែមួយដែលត្រូវសន្មត់ថា ថេត ខ៉ាន់ដែន ជាអ្នកប្រើទូរស័ព្ទនេះ ។ ចំណុចខ្លះទៀតដែលត្រូវស្រាវជ្រាវ សម្លេង មុខមាត់ ភិនភាគមនុស្សទទួលប្រាក់ , លេខរថយន្តពេលចាប់ខ្លួន , ពេលទទួលប្រាក់ ។ល។ ដែលមិនទាន់ឃើញមានស្រាវជ្រាវអ្វីទាំងអស់ ឃើញថាការស៊ើបអង្កេតមិនទាន់មូលទេ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ១១៤ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ដែលបានសំរេច ៖

១ - មិនទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៧-៥-៩៨ របស់មេធាវីការពារជនជាប់ចោទឈ្មោះ ថេត ខ៉ាន់ដែន ហៅ តូ ដោយបណ្តឹងនេះហួសកំណត់ច្បាប់ ។ ផ្អែកតាមមាត្រា១៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២ - សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈ ចំពោះមុខមេធាវីជនជាប់ចោទ កំបាំងមុខជនជាប់ចោទ បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញពាក្យសុំនៅក្រៅឃុំលេខ ២៤៣ ចុះថ្ងៃទី០៣ខែសីហា ឆ្នាំ ១៩៩៨ របស់មេធាវីការពារជនជាប់ចោទឈ្មោះ ថេត ខ៉ាន់ដែន ហៅ តូ ។

- បានឃើញដីកាសំរេចមិនអោយជនជាប់ចោទនៅក្រៅឃុំ លេខ៣៧៦១ ត.ព្រ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២៨ "គ" ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ ១៩៩៨ របស់លោកមេធាវី ជា តារា ដែលប្តឹងតវ៉ាពីដីកាសំរេចលេខ ៣៧៦១ ត.ព្រ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ស៊ើសេចក្តីសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ៖

១ - ទទួលបណ្តឹងឧទ្ធរណ៍លេខ ២៨ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៨ របស់ឈ្មោះ ជា តារា ជាមេធាវីការពារជនជាប់ចោទ ថេត ខ៉ាន់ដែន ហៅតូ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។/

២ - តម្កល់សេចក្តីសំរេចលេខ ៣៧៦១ ត.ព្រ ចុះថ្ងៃទី០៧-៨-៩៨ របស់ចៅក្រមស៊ើបអង្កេត ស្តីពីការមិនអនុញ្ញាតអោយជនជាប់ចោទ ថេត ខាន់ផែន ហៅតូ នៅក្រៅឃុំ ទុកជាបានការតទៅ

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ១៨៤ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ដែលបានសំរេច :

១ - ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ១៩៩៨ របស់មេធាវីឈ្មោះ - ជា តារា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោល ដោយខុសនឹងគតិច្បាប់ ។

២ - តម្កល់ដីកាសំរេចលេខ ៣៧៦១ត.ព្រ ចុះថ្ងៃទី ០៧-៨-៩៨ របស់តុលាការក្រុងភ្នំពេញទុកជាបានការពេញទាំងមូល ។

៣ - សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខមេធាវីការពារជនជាប់ចោទឈ្មោះ ថេត ខាន់ផែន បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ ៣៧ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ១៩៩៨ របស់លោកមេធាវី ជា តារា ការពារអោយជនជាប់ចោទឈ្មោះ ថេត ខាន់ផែន ហៅតូ ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ១៨៤ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណាចុះថ្ងៃទី១០ខែ វិច្ឆិកា ឆ្នាំ១៩៩៨ របស់លោកមេធាវី ជា តារា ការពារអោយជនជាប់ចោទ ជាម្ចាស់បណ្តឹងសាទុក្ខធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានឃើញលិខិតបង្គាប់អោយផ្ញើសារណាឆ្លើយតប ចុះថ្ងៃទី១៨ ខែមករាឆ្នាំ១៩៩៩ របស់តុលាការកំពូល ហើយឈ្មោះ សួ សារិទ្ធ "ជាចុងបណ្តឹងសាទុក្ខ" បានទទួលនៅថ្ងៃទី១៨ ខែមករា ឆ្នាំ ១៩៩៩ ប៉ុន្តែពុំបានដាក់សារណាតបមកតុលាការកំពូលតាមការកំណត់នៃច្បាប់ ។

- បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា :

១ - បណ្តឹងសាទុក្ខរបស់លោកមេធាវី ជា តារា ការពារអោយជនជាប់ចោទ ធ្វើឡើងក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះ មកពិនិត្យពិចារណា ។

២ - ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ ១៨៤ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ។

- បានស្តាប់ចម្លើយអះអាងរបស់ជនជាប់ចោទ នៅពេលជំនុំជំរះថា : ខ្ញុំបាទមិនសុខចិត្តនិងការចោទប្រកាន់មកលើខ្ញុំបាទ ខ្ញុំបានបាត់ទូរស័ព្ទដៃនៅបារបុប្ផាទិព្វ ហើយពុំបានប្តឹងសមត្ថកិច្ចទេ ពេលសមត្ថកិច្ចចាប់ខ្លួនខ្ញុំ គេចោទថាខ្ញុំចាប់មនុស្សជំរិតយកប្រាក់ ព្រោះលេខទូរស័ព្ទដែលចោរប្រើទារប្រាក់ពីជនរងគ្រោះនោះ ជាលេខទូរស័ព្ទរបស់ខ្ញុំដែលបានបាត់ទៅនោះ ខ្ញុំពុំបានដឹងរឿងអ្វីទាំងអស់ សូមតុលាការជួយរកយុត្តិធម៌ដល់ខ្ញុំបាទផង ។

- បានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់លោក ជា តារា មេធាវីការពារអោយជនជាប់ចោទ ជាម្ចាស់បណ្ដឹងសាទុក្ខ នៅពេលជំនុំជំរះថា: ខ្ញុំបានជូនសារណាមកតុលាការកំពូលរួចហើយ ខ្ញុំសូមពរតុលាការពិចារណានូវការរំលោភច្បាប់របស់តុលាការថ្នាក់ក្រោមដោយមាត្រា១៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល តុលាការថ្នាក់ក្រោមពុំបានពិចារណាលើការសុំនៅក្រៅឃុំទេ កូនក្ដីខ្ញុំមានផ្ទះ មានឪពុកម្ដាយ ហើយសន្យានឹងចូលខ្លួនមកតុលាការគ្រប់ពេលវេលា ។ នៅសាលាឧទ្ធរណ៍ដែលយល់ថា " ចំនុចមួយនៃចំនុចទី៤ នៃការយល់ឃើញរបស់ខ្លួន សាលា-ឧទ្ធរណ៍មិនបានពិចារណាលើមាត្រា ១២ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ការសំរេចរបស់សាលាឧទ្ធរណ៍ខុសនិងគតិច្បាប់ ។ សូមតុលាការពិចារណា និងសូមដោះលែងកូនក្ដីខ្ញុំបាទបាននៅក្រៅឃុំបណ្ដោះអាសន្ន ។

- ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ៣៧ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៨ របស់លោក ជា តារា មេធាវីជនជាប់ចោទ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្ដី ។

- យល់ឃើញថា ការដែលតុលាការក្រុងភ្នំពេញ និងសាលាឧទ្ធរណ៍ សំរេចបដិសេធពាក្យសុំអោយដោះលែងជនជាប់ចោទនៅក្រៅឃុំជាបណ្ដោះអាសន្ន របស់មេធាវីជនជាប់ចោទ ដោយអាងហេតុថា រឿងឧក្រិដ្ឋ ទាមទារអោយមានការស៊ើបអង្កេតច្បាស់លាស់ ហើយមាត្រា២២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល កំណត់អោយដោះលែងតែក្នុងករណីប៉ះពាល់ដល់សិទ្ធិនៃការការពារយ៉ាងធ្ងន់ ដែលមិនមែនករណីនៃរឿងព្រហ្មទណ្ឌនេះទេ នោះគឺជាការភ័ន្តច្រឡំ ពីព្រោះថា:

ជនជាប់ចោទត្រូវបាននគរបាលព្រហ្មទណ្ឌឃាត់ខ្លួន ដោយគ្មានដីកាឃាត់ខ្លួនពីសមត្ថកិច្ចតុលាការនិងនៅពេលយប់ម៉ោង១២.០០អធ្រាត្រថែមទៀត ដែលជាការរំលោភទៅនឹងមាត្រា៣៨-៤០ នៃច្បាប់រដ្ឋធម្មនុញ្ញ មាត្រា ៣៥-៣៨-៤៧ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ និងមាត្រា២០នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

នគរបាលបានឃុំខ្លួនជនជាប់ចោទលើសថេរវេលា៤៨ម៉ោងដែលច្បាប់បានកំណត់ គឺឃុំខ្លួនពីថ្ងៃទី២៤-៨-៩៧ រហូតដល់ថ្ងៃទី ០២-៩-៩៧ ទើបបញ្ជូនជនជាប់ចោទទៅព្រះរាជ-អាជ្ញាអមតុលាការក្រុងភ្នំពេញ ដែលជាការរំលោភទៅនឹងមាត្រា១០-១៣ នៃច្បាប់ព្រហ្មទណ្ឌ/

អន្តរកាល និងមាត្រា ៣៨-៤៧ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

ជនជាប់ចោទត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ប៉ុន្តែនៅពេលសួរចម្លើយសមត្ថកិច្ច ពុំបានរកមេធាវីការពារអោយជនជាប់ចោទឡើយ ដែលជាការរំលោភទៅនឹងមាត្រា ៧៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

ជនជាប់ចោទឈ្មោះ ថេត វ៉ាន់ដែន ត្រូវបានឃុំខ្លួនលើសថេរៈវេលា៦ខែ ដែលច្បាប់បានកំណត់ គឺឃាត់ខ្លួននៅថ្ងៃទី ២៤-៨-៩៧ រហូតមកដល់ពេលនេះអស់រយៈពេល ១ឆ្នាំកន្លះមកហើយតុលាការពុំទាន់បានជំនុំជំរះដល់រឿងអង្គសេចក្តីនៅឡើយ ដែលជាការរំលោភទៅនិងមាត្រា១៤-២១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា៦៤នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ។

- យល់ឃើញថា ការមិនគោរពនីតិវិធីខាងលើនេះធ្វើអោយប៉ះពាល់ធ្ងន់ទៅលើសិទ្ធិនៃការការពាររបស់ជនជាប់ចោទដោយពិតប្រាកដ ដែលតាមមាត្រា២២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល តុលាការត្រូវសំរេចដោះលែងជនជាប់ចោទអោយនៅក្រៅឃុំជាបណ្តោះអាសន្ន តាមការស្នើសុំរបស់មេធាវី ។

- យល់ឃើញថា ជនរងគ្រោះបានទទួលលិខិតបង្គាប់អោយធ្វើសារណា ហើយ ប៉ុន្តែពុំបានធ្វើសារណាជូនមកតុលាការកំពូលទេ ហើយក៏ពុំបានចូលរួមនាសវនាការនេះដែរ ដូច្នេះ តុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខជនរងគ្រោះ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១៨៤ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ដែលបានសំរេចមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទ កំបាំងមុខជនរងគ្រោះ
ប៉ុន្តែចាត់ទុកជាចំពោះមុខ

១ - ទទួលបណ្តឹងសាទុក្ខលេខ ៣៧ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៨ របស់លោក ជា តារា មេធាវីជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

២ - ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ ១៨៤ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣ - សំរេចដោះលែងជនជាប់ចោទឈ្មោះ ថេត វ៉ាន់ដែន អោយនៅក្រៅឃុំជាបណ្តោះអាសន្នតាមពាក្យសុំ ។/

៤ - បញ្ជូនឃុំរឿងព្រហ្មទណ្ឌលេខ ៣៨ ចុះថ្ងៃទី ២៥-៩-៩៨ របស់ តុលាការកំពូល ទៅតុលាការក្រុងភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធី ។

៥ - សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ១៩៩៩ ។/